**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## លក្ខខណ្ឌ និង នីតិវិធី ក្នុងការគ្រប់គ្រង
## កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានឃើញ អនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៣៨អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៩ ស្តីពីគ្រប់គ្រង និងការត្រួតពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និង ការប្រើប្រាស់អាវុធជាតិផ្ទុះ គ្រប់ប្រភេទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីល័ក្ខខ័ណ្ឌ និង នីតិវិធីក្នុងការគ្រប់គ្រងកាំភ្លើង គ្រាប់បាញ់

រៀបរៀង ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

និងគ្រឿងផ្ទុះ ដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលប្រកាសដោយព្រះរាជក្រម លេខ នស/រកម/០៦០៥/០១៦ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០០៥ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងការពារសន្តិសុខ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ៣.-**

វិសាលភាពនៃអនុក្រឹត្យនេះគ្របដណ្តប់លើ ការកាន់កាប់ ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការឱ្យខ្ចី ការជួល ការផលិត ការកែច្នៃដំឡើង ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការស្តុកកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់ ។

**មាត្រា ៤.-**

វាក្យសព្ទ ដូចចែងក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចខាងក្រោម ÷

ក. កាំភ្លើងកំណត់សញ្ញា : សំដៅដល់ កាំភ្លើងខ្លី ឬ វែងដែលគេផលិតឡើងក្នុងគោលបំណងដើម្បីបាញ់ចេញបន្លឺសំឡេង ឬ ចេញភ្លើង ផ្សែង សម្រាប់កំណត់សញ្ញា ឬ ទីកន្លែង ។

ខ. កាំភ្លើងកីឡា : សំដៅដល់ កាំភ្លើងខ្លី ឬ វែងដែលគេផលិតឡើងក្នុងគោលបំណង ដើម្បីហាត់ហ្វឹកហ្វឺន ឬ ប្រកួតក្នុងសកម្មភាពកីឡា ។

គ. កាំភ្លើងសិល្បៈ : សំដៅដល់កាំភ្លើងដែលផលិតឡើងក្នុងគោលបំណងប្រើប្រាស់សម្រាប់ការសំដែងសិល្បៈ អាចបាញ់ចេញបន្លឺសម្លេង ឬ អណ្តាតភ្លើងតែគ្មានក្បាលគ្រាប់ ។

ឃ. បំពង់ និងគ្រាប់កាំជ្រួចផ្ទុះលម្អ : សំដៅដល់ ឧបករណ៍ដែលគេផលិតឡើង ក្នុងគោលបំណងដើម្បីបាញ់បញ្ជូនគ្រាប់កាំជ្រួចទៅលើអាកាស ផ្ទុះបន្លឺសម្លេង និង/ឬ បែកចេញផ្កាភ្លើង គ្មានបំណែកអម្បែងលោហៈ ។

ង. គ្រាប់បាញ់ : សំដៅដល់ គ្រាប់ ឬកិបសម្រាប់បាញ់ជាមួយកាំភ្លើងដូចបានចែងក្នុងកថាខណ្ឌ ក.ខ.គ និង ឃ ។

ច. គ្រឿងផ្ទុះ : សំដៅដល់ កិបផ្ទុះ ខ្សែឆ្នួនផ្ទុះ ខ្សែឆ្នួនឆេះ រំសេវ ជាតិផ្ទុះ និង សារធាតុផ្ទុះគ្រប់ប្រភេទ ទោះជាមានដើមកំណើតពីអ្វីក៏ដោយសម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ឬ ផ្ទុះលម្អ ។

គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

## ជំពូកទី ២
## លក្ខខណ្ឌ និង នីតិវិធី
## ក្នុងការគ្រប់គ្រង និងការអនុញ្ញាតឱ្យប្រើប្រាស់

**មាត្រា ៥.-**

កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវចុះបញ្ជីគ្រប់គ្រងតាមគំរូឯកភាពកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦.-**

លក្ខខ័ណ្ឌក្នុងការអនុញ្ញាតឱ្យប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដូចខាងក្រោម ÷

- អ្នកស្នើសុំត្រូវតែជារូបវន្តបុគ្គល ដែលមានសញ្ជាតិខ្មែរ មានអាយុ ១៨ ឆ្នាំឡើង និងមាននីតិសម្បទាគ្រប់គ្រាន់ ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ដែលបានបំពេញបែបបទ និងចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ។
- គោលបំណង និងសំណូមពរ នៃការស្នើសុំ ត្រូវស្របនឹងភាពចាំបាច់ក្នុងមុខរបរ អាជីព ឬ វិជ្ជាជីវៈ ។
- កាំភ្លើង គ្រាប់បាញ់ ឬ គ្រឿងផ្ទុះ ត្រូវបានផលិតឡើងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស មានប្រវត្តិ និងអត្តសញ្ញាណច្បាស់លាស់ ។
- មានការធានាទទួលខុសត្រូវលើផលវិបាកផ្សេងៗ ដែលកើតមានឡើង ។
- គោរពការណែនាំរបស់ក្រសួងមានសមត្ថកិច្ច ពីវិធាននានា ក្នុងការគ្រប់គ្រង ឬកិច្ចការពារសុវត្ថិភាព និរភ័យក្នុងការដឹកជញ្ជូន ការស្តុក និងការបញ្ចេញប្រើប្រាស់ ។
- បំពេញកាតព្វកិច្ចផ្សេងទៀតដែលច្បាប់បានកំណត់ ។

**មាត្រា ៧.-**

នីតិវិធីក្នុងការស្នើសុំលិខិតអនុញ្ញាត ឬ ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.-**

បរិមាណ ប្រភេទ គុណភាពកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះដែលត្រូវផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ ស្របតាមល័ក្ខខ័ណ្ឌ ដូចបានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ ត្រូវពិនិត្យសម្រេចដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៩.-**

កាំភ្លើង គ្រាប់បាញ់ ឬគ្រឿងផ្ទុះ និងលិខិតអនុញ្ញាតទាំងឡាយ ឬប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់ ត្រូវតែបានបង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ចនៅពេលមានសំណូមពរត្រួតពិនិត្យ ។

គេហទំព័រ ឯកសារផ្លូវការ - https://t.me/oa_channel

## ជំពូកទី ៣
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ១០.-**

ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការចែកចាយ ការជួល ការផលិត ការកែច្នៃដំឡើង ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការស្តុកកាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចបានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១១.-**

ការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងគ្រឿងផ្ទុះ សម្រាប់បម្រើសេវាកម្មសាធារណៈ និង វិស្វកម្មស៊ីវិល ដូចបានចែងក្នុងកថាខណ្ឌ ច មាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវដោយក្រសួងមហាផ្ទៃ ។

**មាត្រា ១២.-**

ការដឹកជញ្ជូនគ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និង វិស្វកម្មស៊ីវិលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មធ្យោបាយដឹកជញ្ជូន និង ការពារសុវត្ថិភាព និរភ័យ ត្រូវរ៉ាប់រងដោយកងកម្លាំងនគរបាលជាតិ ។

**មាត្រា ១៣.-**

ឃ្លាំងស្តុកគ្រឿងផ្ទុះត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌបច្ចេកទេសអំពីប្រព័ន្ធការពារសុវត្ថិភាព និរភ័យ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤.-**

ស្ថាប័នសាធារណៈ អង្គការប្រតិបត្តិករ ក្រុមហ៊ុន ការដ្ឋាន កសិដ្ឋាន សិប្បកម្មដ្ឋាន និង អតិថិជនដែលមានតម្រូវការប្រើប្រាស់គ្រឿងផ្ទុះត្រូវសុំអាជ្ញាប័ណ្ណពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៥.-**

ជនណា ដែលប្រព្រឹត្តផ្ទុយពីខ្លឹមសារ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

គេហទំព័រ ឯកសារផ្លូវការ - https://t.me/oa_channel

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ១៦.-**

ក្នុងរយៈពេល ៣ (បី) ខែ យ៉ាងយូរ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ជនណាដែលបាន កាន់កាប់ កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ត្រូវយកមកចុះ បញ្ជីនៅក្រសួងមហាផ្ទៃជាកំហិត ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង ការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវ អនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងអាវុធ

# គ្រឿងផ្ទុះ និង គ្រាប់រំសេវ

តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

# ព្រះរាជក្រម

នស/រកម/០៦០៥/០១៦

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា
- ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់រដ្ឋសភាលើកទី ២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

វិសាលភាពនៃច្បាប់នេះគ្របដណ្តប់លើការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ៣.-**

វាក្យសព្ទ ដូចចែងក្នុងច្បាប់នេះ មាននិយមន័យដូចខាងក្រោម :

ក-អាវុធសំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬ កែច្នៃតម្លើង ដែលអាច ប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ ។

ខ-គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ សម្ភារៈដែលគេផលិត ឬ កែច្នៃតម្លើង ដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ដល់ ទ្រព្យសម្បត្តិ ។

គ-អាវុធគីមី អាវុធជីវសាស្ត្រគ្រប់ប្រភេទ ឬគ្រាប់ដ៏ទៃទៀត ដែលផ្ទុកជាតិគីមីផ្ទុកជីវសាស្ត្រ សំដៅដល់សារធាតុ ដែលគេផលិត ឬ កែច្នៃតម្លើង អាចបង្កគ្រោះថ្នាក់ដល់ សុខភាព អាយុជីវិត ឬ ទ្រព្យសម្បត្តិ និង បរិស្ថាន ។

ឃ-កងកម្លាំងឯកសណ្ឋាន សំដៅដល់កងកម្លាំងនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ។

ង-មន្ត្រី សំដៅដល់អ្នករាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំងឡាយ និង មន្ត្រីតុលាការ មន្ត្រីនៃស្ថាប័នកំពូលរបស់ជាតិ ។

ច-ជនស៊ីវិលសំដៅដល់ជនទាំងឡាយ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ឃ និង ង ។



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

## ជំពូកទី ២

## ការគ្រប់គ្រង ការផ្គត់ផ្គង់

## ការដឹកជញ្ជូន អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ៤.-**

ត្រូវហាមឃាត់ ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទចំពោះជនស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥.-**

ត្រូវបានអនុញ្ញាតឱ្យជនស៊ីវិលប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ក . ខ . គ នៃមាត្រា ៣ ក្នុងច្បាប់នេះ :

- កាំភ្លើង និង គ្រាប់បាញ់កំណត់សញ្ញា
- កាំភ្លើង និង គ្រាប់បាញ់សម្រាប់សកម្មភាពកីឡា
- កាំភ្លើងដែលបាញ់ មិនមានបញ្ចូនក្បាលគ្រាប់ ឬ គ្រាប់ប្រាយ ។ កាំភ្លើងបាញ់បញ្ចូះកាំជ្រួចលំអ ឬ កាំភ្លើងផ្ទុះស្គរគ្មានក្បាលគ្រាប់សម្រាប់សំដែងសិល្បៈ ។
- គ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ឬ សម្រាប់ផ្ទុះលំអ ។

ល័ក្ខខ័ណ្ឌ និង នីតិវិធី សម្រាប់អនុវត្តន៍មាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៦.-**

ត្រូវបានអនុញ្ញាតឱ្យតែក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិមានក្លឹប និង ទីលានសម្រាប់ហាត់បាញ់ដើម្បីហ្វឹកហ្វឺន ។

**មាត្រា ៧.-**

ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើ ពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លង

កាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទដល់កងកម្លាំងឯកសណ្ឋាន និង មន្ត្រី ត្រូវស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨.-**

ជនបរទេស មិនត្រូវបានអនុញ្ញាតឱ្យកាន់កាប់ ឬ ប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

តាមសំណើសុំជាផ្លូវការ រាជរដ្ឋាភិបាលអាចផ្តល់ការលើកលែងចំពោះអង្គរក្សបរទេសមាន : អង្គរក្សរបស់ព្រះមហាក្សត្រ ឬ ព្រះមហាក្សត្រីយានី ប្រធានាធិបតី ប្រមុខរដ្ឋ នាយក- រដ្ឋមន្ត្រី ឥស្សរជនជាន់ខ្ពស់ ដែលយាង ឬ អញ្ជើញមកធ្វើទស្សនៈកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៩.-**

ការចុះបញ្ជីគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ។

**មាត្រា ១០.-**

ក្រសួងការពារជាតិ ទទួលខុសត្រូវលើការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ របស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជនស៊ីវិល ។

**មាត្រា ១១.-**

ក្រសួងការពារជាតិ មានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទដល់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទដល់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជនស៊ីវិល ។

គេហទំព័រ ឯកសារច្បាប់សាធារណៈ - https://t.me/oa_channel

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ត្រូវមានបញ្ជាក់អំពីប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ នឹងល័ក្ខខ័ណ្ឌដែលត្រូវគោរព។

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវរបស់អង្គភាពត្រូវបានបញ្ជាក់បន្ថែម អំពីកាតព្វកិច្ចតម្រូវឱ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវមករក្សាទុកក្នុងឃ្លាំងវិញ ។

នីតិវិធី និង ល័ក្ខខ័ណ្ឌ ស្តីពីការសុំប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១២.-

ក្រសួងការពារជាតិ ទទួលខុសត្រូវលើសុវត្ថិភាព និងសន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើសុវត្ថិភាព និង សន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទរបស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជន ស៊ីវិល ។

អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវទាំងអស់ត្រូវចុះក្នុងបញ្ជី ហើយអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទត្រូវតែស្តុកទុក និងបញ្ចូលក្នុងឃ្លាំងដែលមានសុវត្ថិភាព ។

## មាត្រា ១៣.-

ដើម្បីធានា សុវត្ថិភាពសាធារណៈ និង ដើម្បីបង្ការ ទប់ស្កាត់ គ្រោះមហន្តរាយ ដល់អាយុជីវិត ឬ ទ្រព្យសម្បត្តិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ អាច បញ្ជាឱ្យជន្លៀស សាធារណជន ចេញជាបណ្តោះអាសន្ន ពីលំនៅដ្ឋាន ឬ តំបន់ ក្នុងករណីដឹងថាមានគ្រោះថ្នាក់កើតឡើង ។

បែបបទនៃការអនុវត្តន៏មាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១៤.-

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទក្នុងប្រទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ច របស់ក្រសួងការពារជាតិ បើក្នុងគោលដៅការពារជាតិ . ឬ របស់ក្រសួងមហាផ្ទៃ បើក្នុងគោលដៅការពារ សន្តិសុខផ្ទៃក្នុងប្រទេស ។



ដោយក្រុម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា មកពីក្រៅប្រទេសអាចធ្វើទៅបាន លុះត្រាតែបានការយល់ព្រមពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។

**មាត្រា ១៥.-**

ករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដែលបាននឹងកំពុងកាន់កាប់ ប្រើប្រាស់ ហើយការបាត់នោះកើតឡើងនៅក្រៅអង្គភាព ត្រូវរាយការណ៍មិនលើសពី ២៤ (ម្ភៃបួន)ម៉ោង ក្រោយពេលដឹងថាបាត់ ដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ឬ ប៉ុស្តិ៍កងរាជអាវុធហត្ថ នៅទីកន្លែងដែលបាត់ ហើយត្រូវមានសាក្សីដឹងឮម្នាក់ ឬ ពីរនាក់ទៅជាមួយផងនៅពេលរាយការណ៍ ។ ក្នុងករណីគ្មានសាក្សី សមត្ថកិច្ចនៅកន្លែងកើតហេតុត្រូវចុះត្រួតពិនិត្យ និងធ្វើកំណត់ហេតុដល់ទីកន្លែងដែលបាត់ ។

ករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដែលស្តុកទុកក្នុងឃ្លាំង ឬ ក្នុងអង្គភាព នាយឆ្មាំ ឬ អ្នកទទួលខុសត្រូវថែរក្សាត្រូវរាយការណ៍ដល់មេបញ្ជាការ ឬ ប្រធានអង្គភាព មិនលើសពី ២៤ (ម្ភៃបួន)ម៉ោង ក្រោយដឹងថាបាត់ ។ មេបញ្ជាការ ឬ ប្រធានអង្គភាព ត្រូវចាត់វិធានការត្រួតពិនិត្យស្រាវជ្រាវជាបន្ទាន់ ។

របាយការណ៍ស្តីពីការបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទខាងលើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់លំអិត ទាក់ទង នឹងប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ លេខចុះបញ្ជី ព្រមទាំងមូលហេតុ និង កាលៈទេសៈនៃការបាត់ ។

**មាត្រា ១៦.-**

ការបំផ្លាញអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ឬការលុបចេញពីបញ្ជី ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទនោះ ស្ថិតក្នុងសមត្ថកិច្ច របស់ក្រសួងមហាផ្ទៃ ឬ មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ បើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនោះស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងការពារជាតិ ។



តេលេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**មាត្រា ១៧.-**

ក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាចបង្កើតគណៈកម្មការជាតិ ដើម្បីត្រួតពិនិត្យដឹកនាំឬ កែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការនាំចូល ការនាំចេញ ការជួសជុល
## ការផលិតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ១៨.-**

ការនាំចូល ការនាំចេញ ការជួសជុល ការផលិតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវបានអនុញ្ញាតឱ្យមានរោងជាងជួសជុលនិងទីតាំងសម្រាប់ធ្វើការសាកល្បងគុណភាពអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

ការនាំចូល ការនាំចេញ ការផលិតអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ត្រូវស្របតាមគោលការណ៍ និងវិធានទាំងឡាយរបស់អន្តរជាតិដែលពាក់ព័ន្ធ ។

## ជំពូកទី ៤
## ទោសប្បញ្ញត្តិ

**មាត្រា ១៩.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងមាត្រា ១៥ និងមាត្រា ១៦ នៃច្បាប់នេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ខែ ដល់ ១(មួយ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០,០០០ (ម្ភៃម៉ឺន)រៀល ដល់ ១.០០០.០០០ (មួយលាន)រៀល ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ២០.-**

ជនណាដែលបំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ដូរ កែច្នៃតម្លើង ជួសជុល នូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោស



គេហទំព័រ ឯកសារច្បាប់សាធារណៈ - https://t.me/oa_channel

ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់ ២(ពីរ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ហាសិបម៉ឺន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ២១.-**

ជនណាដែលធ្វេសប្រហែស ឱ្យជនដទៃ យកអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ ដែលខ្លួនកាន់កាប់ទៅប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ដល់ ២ (ពីរ)ឆ្នាំនិងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៧០០.០០០ (ចិតសិបម៉ឺន)រៀល ដល់ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២២.-**

មន្ត្រីដែលក្រសួងមានសមត្ថកិច្ច ប្រគល់ឱ្យចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ តែការផ្តល់ប័ណ្ណសម្គាល់សិទ្ធិ ប្រើប្រាស់នោះ ពុំបានត្រឹមត្រូវខុសសមត្ថកិច្ចរបស់ខ្លួនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.០០០.០០០ (បីលាន)រៀល ដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ជនណាដែលពុំមែនជាសមត្ថកិច្ច ហើយបានចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទក្រោមរូបភាពណាមួយ ឬ ដោយមូលហេតុណាក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ៨(ប្រាំបី)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជា ប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

ជនណាដែលធ្វើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយក្លែងបន្លំ ឬ បានប្រើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយដឹងថាក្លែងបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់១០(ដប់)ឆ្នាំ ។

**មាត្រា ២៣.-**

ជនណាដែលផលិត ធ្វើពាណិជ្ជកម្ម នាំឆ្លងកាត់ នាំចេញ នាំចូល ឬ ស្តុកនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ។

**មាត្រា ២៤.-**

ជនណាដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា ៨ និងមាត្រា ១៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**មាត្រា ២៥.-**

ក្នុងរយៈពេល ៣ (បី)ខែ យ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ជនណាដែលបានកាន់កាប់ អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតត្រូវយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទទាំងនោះ មកប្រគល់ឱ្យអាជ្ញាធរមានសមត្ថកិច្ច ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៧.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

ពរស. ០៥០៦.២៦៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ ២២៤ ច.ល

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា និងព្រះហស្តលេខា**

**ស ខេង នរោត្តម សិរីវុឌ្ឍ**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា**

**ណាវ ឥនាន់**



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel